## ខ្លឹមសារសង្ខេបសេចក្តីសម្រេច

***Ameilda De Quinteros v. Uruguay*, Human Rights Committee (HRC), UNDoc CCPR/C/19/D/107/1981, 21 July 1983**

**<u>ពាក្យគន្លឹះ</u>៖** ការដកហូតសិទ្ធិសេរីភាព, បាត់ខ្លួនដោយបង្ខំ ការប្រព្រឹត្តមិនគម្បី, Psychological torture, secondary victim

១. ជនជាតិអ៊ុយរ៉ាហ្គាយ (Uru) ជាសមាជិកបក្សនយោបាយ រត់ចូលក្នុងស្ថានទូតប្រទេស វេណេស៊ុយអេឡា (Ve) ក្នុងទីក្រុង Montevideo នៃប្រទេស Uru តែត្រូវបានមន្ត្រី Uru ចូលទៅចាប់មកវិញ ដែលអំឡុងពេលចាប់ បានប្រតាយប្រតប់នឹងមន្ត្រីទូត Ve។[1] នាងត្រូវបានឃុំខ្លួន ប្រព្រឹត្តមិនគម្បី និងរងទារុណកម្មធ្ងន់ធ្ងរ។ មិនមានដំណឹងថាស្លាប់ឬរស់ទេ មកដល់ពេលដាក់ពាក្យបណ្តឹងនេះ (communication)។ ម្តាយរបស់នាង ដែលរស់នៅប្រទេស Sweden បានដាក់ពាក្យបណ្តឹងមកគណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ (United Nations Human Rights Committee :UNHRC) ក្នុងនាមខ្លួនជាជនរងគ្រោះ និងតំណាងឲ្យកូនស្រីផង (កថា ១.១) ដោយចោទ Uru ថាបានបំពានមាត្រាទី ៧, ៩,១០,១២,១៤, ១៧ និង ១៩ នៃកតិកាសញ្ញាស្តីពីសិទ្ធិប្រជាពលរដ្ឋ (ICCPR) (កថា ១.៩)។

២. គណៈកម្មាធិការ បានពិចារណានូវអង្គហេតុ និងព័ត៌មានដាក់ជូនពិនិត្យដោយភាគី ហើយបានអះអាងថា៖ *មាត្រា ៤(២) នៃពិធីសារជម្រើស (Optional Protocol) ចែងដោយប្រយោលនូវកាតព្វកិច្ចរបស់រដ្ឋភាគី ធ្វើការស៊ើបអង្កេតដោយសុទ្ធចិត្ត នូវការចោទថាបានបំពានសិទ្ធិ ដោយអាជ្ញាធររបស់ខ្លួន ....*។[2] ការចាប់ខ្លួន ឃុំខ្លួន និងធ្វើទារុណកម្ម ដោយគ្មានគោរពតាមនីតិវិធីច្បាប់ ឬការពិនិត្យ ពិចារណារបស់តុលាការ បំពានមាត្រាទី៧ (ការហាមឃាត់ ការប្រព្រឹត្តមិនគម្បី និងទារុណកម្ម) មាត្រាទី៩ (ការពិនិត្យដោយតុលាការ លើភាពស្របច្បាប់នៃការឃាត់ ចាប់ ឬឃុំខ្លួន) និងមាត្រា ១០ (លក្ខខណ្ឌនៃការឃុំខ្លួន) (កថា. ១៣)។

៣. គណៈកម្មាធិការ បានរកឃើញថា ក្រោយពីថ្ងៃចាប់ខ្លួន និងគ្មានដំណឹងអំពីកូន អ្នកប្តឹង (ម្តាយ) ទទួលរងនូវវិបត្តិផ្លូវចិត្ត តានតឹងអារម្មណ៍ ហើយទង្វើនេះជ្រៀតជ្រែកជីវិតឯកជននៃគ្រួសារ។ ទាំងនេះ ប៉ះនឹងសិទ្ធិទទួលបានព័ត៌មានពាក់ព័ន្ធជោគវាសនារបស់កូនស្រី។ គណៈកម្មាធិការរកឃើញថា ជាការបំពានសិទ្ធិចែងក្នុងមាត្រាទី ៧ របស់អ្នកប្តឹង (កថា.១៤)។

**<u>កំណត់សំគាល់</u>៖ ក.** ក្នុងរឿងនេះ គណៈកម្មាធិការ ទទួលស្គាល់នូវ ជនរងគ្រោះនៃអំពើទារុណកម្មផ្លូវចិត្ត (psychological torture) ដែលជា secondary victim។[3] នេះជួយបញ្ជាក់បំភ្លឺ នូវការយល់ច្រឡំទទួលស្គាល់ថាមានតែទារុណកម្មផ្លូវកាយប៉ុណ្ណោះ។ **ខ.** គណៈកម្មាធិការ នៅតែទទួលបណ្តឹង (admissible) ទោះបី

---

[1] Not only does this action constitute a flagrant violation of the right of asylum but, in addition, the Uruguay police authorities assaulted two diplomatic representatives of our country, thus violating the most elementary rules of diplomatic immunity and international courtesy, para. 10.7(ii).

[2] Para. 11.: …The Committee reiterates that it is implicit in article 4(2) of the Optional Protocol that the State party has the duty to investigate in good faith all allegations of violation of the Covenant made against it and its authorities, …

[3] Oxford Reports on International Human Rights Law, http://opil.ouplaw.com

ការប្រព្រឹត្តបំពានកើតមុន ពេលទទួលស្គាល់របស់ Uruguay នូវសមត្ថកិច្ចរបស់គណៈកម្មាធិការ ក្នុងការពិនិត្យពាក្យបណ្ដឹងចូលជាធរមានសម្រាប់ប្រទេសនេះ ដោយផ្អែកលើមូលដ្ឋានថា ការឈឺចាប់កើតពីការបំពានសិទ្ធិ នៅតែមានជាបន្ត ( កឋា. ៧.៣)។